ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជម្លូខ្មៅ
## រយៈពេល ៣ឆ្នាំ ( មករា ២០២៦ - ធ្នូ ២០២៨ )

ឈ្មោះសហគមន៍នេសាទ ៖ ជម្លូខ្មៅ
ភូមិ ៖ ជម្លូខ្មៅ
ឃុំ ៖ ទួលទទឹង
ស្រុក ៖ ព្រៃនប់
ខេត្ត ៖ ព្រះសីហនុ

រៀបចំដោយរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផលកំពង់សោម (គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ


**១- ស្ថានភាពទូទៅ**..........១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**..........២

ក- ប្រជាពលរដ្ឋ..........២

ខ-មុខរបរ..........២

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងសហគមន៍នេសាទ**..........៣

ក- ទីតាំង..........៣

ខ- ដែននេសាទ..........៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល..........៣

ឃ- ធនធានជលផល..........៤

**៤- ការធ្វើនេសាទ**..........៤

ក- អ្នកនេសាទ..........៤

ខ- ឧបករណ៍នេសាទ..........៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ..........៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**..........៦

**ក- ទស្សនៈវិស័យ**..........៦

**ខ- គោលបំណង**..........៦

**គ-ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**..........៦

**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**..........៦

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ..........៦

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ..........៧

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល..........៨

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ..........៩

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល..........១០

គ៦- ផែនការកែលម្អកន្លែងសហគមន៍នេសាទ..........១១

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ..........១២

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ..........១៣

គ៩- ផែនការគ្រប់គ្រងព្រៃកោកាង..........១៣

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**..........១៤

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ..........១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ..........១៦

គ១២- ផែនការបង្កើតតំបន់ទេសចរណ៍ជលផលរបស់សហគមន៍នេសាទ..........១៧

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ..........១៨

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**......................១៩

គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ............១៩

គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ..................................................២០

**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**..............................................................................២០

គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន..................................................................២០

គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍.......................................................២១

**ឃ. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**.............................................................................២២

**ង. ផែនការយុទ្ធសាស្ត្រ**...........................................................................................................២២

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជំពូខ្មៅ រយៈពេល៣ឆ្នាំ**..........................២៣

**តារាងពេលវេលាការងារ**...........................................................................................៣២

# ផែនការគ្រប់គ្រង
# កន្លែងសហគមន៍នេសាទ

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទជំពូខ្មៅ បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ព្រមទាំងត្រូវបានចុះបញ្ជីទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយប្រកាសលេខ៥៧៩ ប្រក.កសក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០។

សហគមន៍នេសាទជំពូខ្មៅ មានទីតាំងស្ថិតនៅភូមិជំពូខ្មៅ ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ដែលមានសមាជិកសរុបចំនួន ២០០ នាក់ ស្រី ៩៨ នាក់ ក្នុងនោះគ្រួសារ សរុបមានចំនួន ១៥២ គ្រួសារ។ មានគណៈកម្មការចំនួន១១នាក់ ស្រី២នាក់ និងមានក្រុមល្បាតចំនួន៨នាក់ ។

កន្លងមកសហគមន៍នេសាទជំពូខ្មៅ បានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ បានកំណត់ព្រំប្រទល់ផែនទីកន្លែងសហគមន៍នេសាទ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដោយបែងចែកតួនាទីនិងភារកិច្ចការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ មានការទទួលស្គាល់ឯកភាពពីភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន។ ការអនុវត្តផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទគឺគណៈកម្មការ និងសមាជិកសហគមន៍នេសាទបានសហការជាមួយដៃគូពាក់ព័ន្ធដោយបានអនុវត្តសកម្មភាពសំខាន់ៗរួមមានការចូលរួមប្រជុំនិងបិទផ្សាយផែនទីកន្លែងសហគមន៍នេសាទ រៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ ផ្តួចផ្តើមសកម្មភាពមុខរបរ ចូលរួមយុទ្ធនាការផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនានា រៀបចំក្រុមល្បាត និងចុះល្បាតដោយសហការជាមួយសមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមានក្នុងកន្លែងសហគមន៍នេសាទ។ សកម្មភាពទាំងនេះ សបញ្ជាក់ពីការប្រឹងប្រែងអនុវត្តសកម្មភាព ស្របតាមផែនការគ្រប់គ្រងរបស់ខ្លួនទៅតាមធនធានដែលមានកំណត់។ បច្ចុប្បន្នសហគមន៍នេសាទជំពូខ្មៅ កំពុងខិតខំគៀងគរការចូលរួមធនធាននិងការគាំទ្រនានាក្នុងការដោះស្រាយបញ្ហាប្រឈមដែលនៅតែកើតមានឡើងដូចខាងក្រោម៖

- ផលនេសាទថយចុះបណ្តាលពីសកម្មភាពនេសាទលើសកម្រិត ការនេសាទដោយប្រើប្រាស់ឧបករណ៍លបកន្ទុយកណ្តុរ តម្រូវការផលនេសាទកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញ ដូចជា ការប្រើប្រាស់ឧបករណ៍ឆក់ជាដើម ព្រមទាំងការប្រជែងគ្នាក្នុងការនេសាទរវាងសកម្មភាពនេសាទខ្នាតតូចនេសាទជាប្រពៃណី និងនេសាទខ្នាតធំ។ សហគមន៍នេសាទសង្កេតឃើញថា បញ្ហានេះបានជះឥទ្ធិពលដល់ផលចាប់ត្រីនិងវារីសត្វសមុទ្រផ្សេងៗមានការថយចុះ
- ការថយចុះប្រព័ន្ធអេកូឡូស៊ីជលផលសមុទ្រ ដូចជា ជម្រកសុវត្ថិភាព ព្រៃកោងកាង ដែលកំពុងរងផលប៉ះពាល់ពីការនេសាទដែលបំផ្លិចបំផ្លាញ ការប្រើប្រាស់ដីមិនសមស្រប ជាដើម
- សមត្ថភាពនិងចំណេះដឹងរបស់គណៈកម្មការ និងសមាជិកសហគមន៍នេសាទនៅមានកម្រិត ដូចជា ខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងខ្វះការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋានឬសហគ្រប់គ្រងនៅមានកម្រិត ដូចជាការងាររដ្ឋបាល ការអនុវត្តសកម្មភាពការងារគ្រប់គ្រងការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត

- លទ្ធភាពចូលរួមអនុវត្តច្បាប់មានកម្រិតដោយខ្វះមធ្យោបាយ ដូចជា ឧករណ៍ទំនាក់ទំនងរាយការណ៍ ទូកល្បាត ដែលធននឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ស្តីពីជលផលមិនបានដិតដល់ជាប្រចាំ
- ការជ្រើសរើសមុខរបរនៅមានកម្រិត និងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយ និងផលចាប់ពីធម្មជាតិ  អស្ថេរភាពតម្លៃផលិតផលកសិកម្មដែលកំណត់ដោយឈ្មួញកណ្តាលក្នុងតំបន់  ពិបាកក្នុងការទទួលបានតម្លៃបន្ថែមលើផលផលិតផលដោយសារគុណភាពផលិតផលនិងការកែច្នៃ ខ្វះទន់ក្នុងការចាប់ផ្តើម និងជំនាញលើមុខរបរ ដូចជាការបង្កើតសេវាទេសចរណ៍ជលផល វារីវប្បកម្មដែលមិនប្រើចំណីជាដើម
- ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិបានប៉ះពាល់ការប្រកបមុខរបរនេសាទ ទេសចរណ៍ជលផល លំនៅដ្ឋាន និងគុណភាពទឹកសមុទ្រ ដូចជា កំណើនជាតិពុលក្នុងទឹក កំដៅទឹកសមុទ្រអាចនឹងប៉ះពាល់ដល់វារីវប្បកម្ម
- ការបង្ហូរជាតិពុលពីរោងចក្រ  ការចោលសំរាមផ្លាស្ទីក  និងកាកសំណល់នានាដែលនាំឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ បង្កឱ្យមានជាតិពុល និងសោភណ្ឌភាពនៅក្នុងសហគមន៍នេសាទ។

ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទជំពូខ្មៅ ឆ្នាំ២០១១ ដល់ ឆ្នាំ២០១៣ លេខ១២៤១ ជផ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ត្រូវបានរៀបចំកែសម្រួលឡើងវិញ ដោយធ្វើបច្ចុប្បន្នភាពនូវទិន្នន័យសហគមន៍នេសាទ សកម្មភាពនានាស្របនឹងនិន្នាការថ្មីៗ តាមតម្រូវការសហគមន៍ និងការប៉ាន់ប្រមាណថវិកា ដោយផ្តោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការគ្រប់គ្រងសកម្មភាពនេសាទ និងការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទប្រកបដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ស្របតាមប្រការ៣០ នៃប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំសហគមន៍នេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន៩៧៣ នាក់ ស្រី៤៨០ នាក់ ក្នុងនោះមានចំនួន ១៥២ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរ ១០០ នាក់ ស្រី ៥០ នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ៨១ នាក់ ស្រី ៣៧ នាក់ កម្រិតវិទ្យាល័យចំនួន ១៩ នាក់ ស្រីចំនួន ១១ នាក់ និងកម្រិតឧត្តមសិក្សាគ្មាន ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន៨នាក់ ស្រី១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី២នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន៣១នាក់ ស្រី៧នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី២នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទ　　ចំនួន១៥២ គ្រួសារ
- ធ្វើស្រែ　　ចំនួន ១០០ គ្រួសារ　　សរុបទំហំ ២៦៥ ហិកតា
- ធ្វើចំការ　　ចំនួន១០ គ្រួសារ　　សរុបទំហំ ១១ ហិកតា

- ដាំបន្លែ ចំនួន៧០ គ្រួសារ សរុបទំហំ ១០ ហិកតា
- ធ្វើវារីវប្បកម្ម ចំនួន១៥ គ្រួសារ
- ជាងផ្ទះ ចំនួន ១០គ្រួសារ
- ធ្វើសិប្បកម្ម ចំនួន១ គ្រួសារ
- លក់ដូរ ចំនួន១២ គ្រួសារ
- កម្មករចល័ត ចំនួន៥០ គ្រួសារ
- កែច្នៃផលិតផលជលផល ចំនួន៣ គ្រួសារ (បង្គាក្រៀម ក្តាមប្រៃ និងត្រីងៀត)
- ចិញ្ចឹមសត្វ ចំនួន១២៧គ្រួសារ ។

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៦ ៨០០ ០០០ រៀល ។

## ៣ កន្លែងសហគមន៍នេសាទ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងសហគមន៍នេសាទជំពូខ្មៅ ជាតំបន់គ្រប់គ្រងជលផលសមុទ្រ មានព្រៃកោងកាង វាលភក់ ព្រែក និងដៃព្រែក ស្ថិតនៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ **២៦៧០** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងកន្លែងសហគមន៍នេសាទបន្ទាយប្រិយ និងកន្លែងសហគមន៍នេសាទព្រៃនប់ពីរ
- ខាងត្បូងទល់នឹងកន្លែងសហគមន៍នេសាទបែកក្រង់
- ខាងកើតទល់នឹងកន្លែងសហគមន៍នេសាទព្រៃនប់ពីរ
- ខាងលិចទល់នឹងឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

### ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទជំពូខ្មៅ មានលំហរសមុទ្រ វាលភក់ ព្រែកចំនួន៣ព្រែក ប្រឡាយចំនួន៣ប្រឡាយ និងនាទីព្រៃកោងកាងស្ថិតនៅក្នុងសហគមន៍នេសាទគឺ៖

- លំហរផ្ទៃទឹកសមុទ្រ ទំហំ ១០២៣ ហិកតា នេសាទពេញមួយឆ្នាំ
- ក្នុងនោះមានវាលភក់ ទំហំ ៤៥៣ ហិកតា នេសាទពេញមួយឆ្នាំ (ទឹកជោនាជ)
- ព្រែកកណ្តាល ទំហំ ២ម x ១៥០០ម នេសាទពេញមួយឆ្នាំ
- ព្រែកឆាលី ទំហំ ៣ម x ៨០០ម នេសាទពេញមួយឆ្នាំ
- ព្រែកទទឹងថ្ងៃ ទំហំ ៣-៤ម x ៦០០ម នេសាទពេញមួយឆ្នាំ
- ប្រឡាយទទួលទទឹង ទំហំ ៧ម x ៦០០០ម នេសាទពេញមួយឆ្នាំ
- ប្រឡាយព្រៃនប់ ទំហំ ១២ម x ៧០០ម នេសាទពេញមួយឆ្នាំ
- ប្រឡាយជីកថ្មី ទំហំ ៨ម x ៨០០ម នេសាទពេញមួយឆ្នាំ
- ព្រៃកោងកាង ទំហំ ២១៤ ហិកតា នេសាទពេញមួយឆ្នាំ។

### គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

- នាទីព្រៃកោងកាងស្ថិតក្នុងកន្លែងសហគមន៍នេសាទ ទំហំ ៥៥ ហិកតា
- វាលភក់ជាប់ព្រំប្រទល់សហគមន៍នេសាទជំពូខ្មៅ ទំហំ ៧ ហិកតា។

**ឃ. ធនធានជលផល**

- **ប្រភេទត្រី ៖** ត្រីក្តចិន ត្រីក្បក ត្រីក្អុក ត្រីឆ្លាធូ ត្រីម្រេច ត្រីស្លុង ត្រីក្រហម ត្រីឆ្ដោង ត្រីត្រសក់ ត្រីឆ្លាម ត្រីបបែល ត្រីកាវ៉ាវ ត្រីឆ្ដោង ត្រីកញ្ជាក់ស្លា ត្រីប្រម៉ា ត្រីភ្នែកឡាន ត្រីអណ្តែងប៉ុយ ត្រីកន្ធាំង ត្រីកន្ធុយរឹង ត្រីបេកា ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីបាឃើ ត្រីអង្រែ ត្រីទក់សមុទ្រ សំពោច ប្រកុង អន្ទង់ទឹកភ្លាវ។ល។

**ប្រភេទត្រីទឹកសាប** ៖ ស្លាត អណ្តែង ផ្ទក់ ក្រាញ់ កំភ្លៀញ កន្ត្រប់ ទីឡាបព្យ៉ា ចង្វា ក្រឹម។ល។

- **ប្រភេទវារីសត្វ ៖** បង្គា បង្កង បង្កងកន្ទប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹកគ្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ធាយ ប័លង្លងកាស កញ្ជ្រា អន្ទង់ ខ្ចឹង ពស់សាមឡាន់ ពស់ទឹក ពស់ខ្មៅ ពស់វែក ផ្សោតស ផ្សោតខ្មៅ ផ្សោតប៉ាវ៉ា វមិច បង្គ្រប ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក ព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៊ុង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ដើមឡៀវអាវ ចាក ប្រង់ ដើមដូងទឹក។ល។

## ៤. ការធ្វើនេសាទ

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២០០នាក់ ស្រី៩៨នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍១០០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន២០០នាក់ ។

**ខ. ឧបករណ៍នេសាទ ៖**

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៣៥ | ១៥០០ម៉ែត្រ /គ្រួសារ | ក្រឡា៣,៥ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីកាវាវ | ម៉ែត្រ | ៧ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| លបក្តាមថ្ម | លប | ៩ | ៥០០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| លបក្តាមសេះ | លប | ៨ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| សន្ទូចរនងត្រី | ផ្លែ | ៧ | ១០០-២០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | ឧសភាដល់ធ្នូ |
| បង្កៃ | ផ្លែ | ២០ | ១៥០ផ្លែ/គ្រួសារ | ផ្លែលេខ៦-៨ | ឧសភាដល់ធ្នូ |
| ឈិបរុញដោយដៃ | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ក្រឡា១,៥ស.មឡើង | ពេញរដូវនេសាទ |
| វាវគ្រែងឈាម | នាក់ | ៣០ | ២០០នាក់ | - | ពេញរដូវនេសាទ |
| វាវងាវភក់ | នាក់ | ២០ | ២០០នាក់ | - | ពេញរដូវនេសាទ |
| លូកក្តាមថ្ម ជ័រ | នាក់ | ១០ | ២០០នាក់ | - | ពេញរដូវនេសាទ |
| មងត្រី | ម៉ែត្រ | ២០ | ១០០០ម៉ែត្រ/គ្រួសារ | ក្រឡា ១០ ស.មឡើង | ឧសភាដល់ធ្នូ |
| លបត្រី | លប | ១០ | ១០-២០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ឧសភាដល់ធ្នូ |
| ទ្រូ | ទ្រូ | ៣ | ៩ទ្រូ/គ្រួសារ | - | ឧសភាដល់ធ្នូ |
| សំណាញ់ | វង់ | ៦ | ១៥វង់/គ្រួសារ | ក្រឡា១,៥ស.មឡើង | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៤៧ គ្រឿង | ៥០០-១៥០០គីឡូក្រាម | ៥-១៣ សេះ |
| ទូកអុំនិងចែវ | ៤គ្រឿង | ៥០-១០០គីឡូក្រាម | - |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ២៣ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៣,៥ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីតាវ | ម៉ែត្រ | ៨ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងក្ដាម | ម៉ែត្រ | ៨ | ៣០០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| មងត្រីកន្ដាំង | ម៉ែត្រ | ៩ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៤ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីឆ្ពង់ | ម៉ែត្រ | ៨ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសាទ |
| លបក្ដាមសេះ | លប | ៧ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| លបក្ដាមថ្ម | លប | ៨ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| សន្ទូចត្រីក្អុក | ផ្លែ | ៥ | ៣០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | មេសាដល់កក្កដា |
| សន្ទូចត្រីអណ្ដែងប៉ុយ | ផ្លែ | ៤ | ៣០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | មេសាដល់កក្កដា |
| សន្ទូចបបែល | ផ្លែ | ៥ | ៥០០ផ្លែ/គ្រួសារ | - | មេសាដល់កក្កដា |
| រាវគ្រែងឈាម/ងាវភក់ | នាក់ | ៥ | ១នាក់ | - | ពេញរដូវនេសាទ |
| ឈិបរុញដោយដៃ | គ្រឿង | ២ | ១គ្រឿង/គ្រួសារ | - | ពេញរដូវនេសាទ |
| សំណាញ់ | វង់ | ៥ | ១វង់/គ្រួសារ | ក្រឡា១,៥ស.មឡើង | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៣៥ គ្រឿង | ៧០០-១.០០០គីឡូក្រាម | ៦-១៣ សេះ |
| ទូកអុំនិងចែវ | ២៣ គ្រឿង | ១០០-១៥០គីឡូក្រាម | - |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងក្ដាម | ម៉ែត្រ | ៧៥ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| មងត្រីឆ្ពង | ម៉ែត្រ | ៤០ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសា |
| លបក្ដាមសេះ | លប | ៣៣ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| លបក្ដាមថ្ម | លប | ៣២ | ៥០០លប/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| ឈិបរុញដោយដៃ | គ្រឿង | ២០ | ១គ្រឿង/គ្រួសារ | - | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥០ គ្រឿង | ៥០០-១.០០០គីឡូក្រាម | ៦-១៣ សេះ |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| **ប្រភេទផលនេសាទ** | **បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ)** | | |
|---|---|---|---|
| | **រដូវប្រាំង** | **រដូវវស្សា** | **សរុបប្រចាំឆ្នាំ** |
| ត្រីចម្រុះ | ៩០ គីឡូក្រាម | ២០០ គីឡូក្រាម | ២៩០ គីឡូក្រាម |
| បង្គា | ១២៥ គីឡូក្រាម | ២០៥ គីឡូក្រាម | ៣៣០ គីឡូក្រាម |
| ក្ដាម(ថ្ម សេះ ជ័រ) | ៤២០ គីឡូក្រាម | ៧៦០ គីឡូក្រាម | ១១៨០ គីឡូក្រាម |
| ងាវភក់ និងគ្រែងឈាម | ៣៥០ គីឡូក្រាម | ១៣០ គីឡូក្រាម | ៤៨០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទជំពូខ្មៅ មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ដែលជាកន្លែងសហគមន៍នេសាទ នាទីព្រៃកោងកាង វាលភក់ និងកន្លែងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**

**ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង**

**គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចកែងបំបែកជា៣ ជាប់ខាងលិចសាលាឆទានក្នុងភូមិ ទំហំ១២ម x១៣ម (374041-1174101, 374029-1174103) ភូមិជំពូខ្មៅ ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបានរៀបចំដូចខាងក្រោម ៖

| **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **ប៉ាន់ប្រ មាណតម្លៃ (ដុល្លារ)** | **អ្នកចូលរួម** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|
| បោះបង្គោលបេតុងចំណាំ ដោយសរសេរអក្សរលើបង្គោល ២ បង្គោល (ទំហំ១០ស.មx១០ស.មx១ម) | ដីបម្រុងទុកសម្រាប់សាងសង់ស្នាក់ការសហគមន៍នេសាទជំពូខ្មៅ | ១០ | សហគមន៍នេសាទ អាជ្ញាធរភូមិ ឃុំ អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |
| ប្រជុំជាមួយអ្នកពាក់ព័ន្ធ | -មានការចូលរួម | ២០០ | សហគមន៍នេសាទ | មករា | ធ្នូ |

| | | | | | |
|---|---|---|---|---|---|
| | -មានការគាំទ្រ | | ស្ថាប័នពាក់ព័ន្ធ<br>អង្គការដៃគូ | ២០២៦ | ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១២មធ្វើពីបេតុង គ្រឿងដែកប្រក់ហ្វីប្រូស៊ីម៉ង់ បន្ទប់មួយជ្រុងរៀបជញ្ជាំងរៀបឥដ្ឋ ដោយតយ៉ាបបីជ្រុង និងមានបង្គន់អនាម័យ បុរស ស្ត្រី | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងសហគមន៍នេសាទ | ១៥០០០ | សហគមន៍នេសាទ<br>ស្ថាប័នពាក់ព័ន្ធ<br>អង្គការដៃគូ | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| រៀបចំតបណ្តាញអគ្គីសនី | មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ | ៣០០ | | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| រៀបចំប្រព័ន្ធទឹកស្អាត | មានទឹកស្អាតប្រើប្រាស់ | ១២០០ | | | |
| ទិញសម្ភារសហគមន៍នេសាទ<br>(តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារសម្រាប់ស.នធ្វើការ | ១៥៥០ | | | |

(ស.ន = សហគមន៍នេសាទ, ម = ម៉ែត្រ, ស.ម = សង្ទីម៉ែត្រ)

**គ២- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ**

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី១នៃខែរៀងរាល់ខែ ឬត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| ប្រជុំជាមួយអាជ្ញាធរឃុំ ស្រុក ឬស្ថាប័នពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែរបស់ស.ន<br>-បញ្ចូលផែនការក្នុងផែនការឃុំ | ៦៥០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| ចូលរួមប្រជុំជាមួយបណ្តាញស.ន ថ្នាក់ស្រុក ឬថ្នាក់ខេត្ត | | | -អាជ្ញាធរស្រុក/ខេត្ត<br>-បណ្តាញស.ន | | |
| ចុះអនុវត្តន៍សកម្មភាពជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ | - ចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន<br>- ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសជលផលថយចុះ | ៦០០ | គណៈកម្មការ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | -មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ | ៩០០ | -គណៈកម្មការ<br>-សមាជិកស.ន | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| សម្ភារការិយាល័យ៖<br>ទិញក្រដាស់ ប៊ិច ព្រីនឯកសារ កូពី ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ៨០០ | គណៈកម្មការ | | |

(ស.ន = សហគមន៍នេសាទ)

### គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី ៖<br>-ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីសហគមន៍កសិកម្ម ឯកសារគតិ យុត្តិនានាពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ<br>-ការរៀបចំនិងទុកដាក់សម្រាម<br>-បទពិសោធន៍នានាទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហកមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | ២៥៨០ | គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | ឧសភា-ធ្នូ/ រៀងរាល់ឆ្នាំ | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | មករា ២០២៦ | ធ្នូ ២០២៨ |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៥០០ | | | |
| ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជីទូកម៉ាស៊ីន | សមាជិកសហគមន៍នេសាទ បានចុះបញ្ជីទូកម៉ាស៊ីនតាមច្បាប់ | ៥០០ | | មករា ២០២៦ | ធ្នូ ២០២៨ |
| ២.ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ និងរបាយការណ៍<br>-គម្រោងស្នើសុំថវិកានិងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការ និងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១០០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មករា ២០២៦ | ធ្នូ ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈកម្មការស.ន (២នាក់) | ៥០០ | គណៈកម្មការស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ដោយការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទ បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | | ៤០០ | គណៈកម្មការ ជំនាញជលផល | | |

(ស.ន = សហគមន៍នេសាទ)

### គ.៤ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទកន្លែងនេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍ជំពូខ្មៅ | ពេញរដូវនេសាទ | មងត្រីក្បក | ក្រឡា ៣,៥ស.មឡើង | ៥០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | មងត្រីឆ្តង | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្អុក | ក្រឡា ៩ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីអណ្តាតឆ្កែ | ក្រឡា ៥,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីចាប | ក្រឡា ៦ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបបែល | ក្រឡា ១៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីព្រលួស | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីប្រខុប ឬត្រីកាម៉យ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាប៉ាស់ ឬត្រីដូរអង្ករ | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្បាន្ត | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីផ្ទោង | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្តាំង | ក្រឡា ៤ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងក្តាម | ក្រឡា ៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងប៉ាកាំង ឬបង្កងកន្ទប | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាម៉ុង | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្ទុយរឹង | ក្រឡា ៤,៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីការ៉ាវ | ក្រឡា ៧ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបេកា | ក្រឡា ៨ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងត្រីសំប៉ាន | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីគូន | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា១ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា៣ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងហ៊ុម | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | លបមឹក | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបក្តាម | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបបង្គា | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបខ្យង | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបត្រី | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបត្រីតុកកែ | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបប្រឹសច្រើន/កន្ទុយកណ្តុរ | ក្រឡា ៣ ស.មឡើង | ២០លប/គ្រួសារ | |
| | | អួនត្រីស | ក្រឡា ២,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនត្រីកាឡេងតេង | ក្រឡា ១,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនហ៊ុមកៀនច្រាំង | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនខ្ចូវ ឬមងខ្ចូវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| កន្លែងនេសាទ សហគមន៍ ជំពូខ្មៅ | ពេញ រដូវនេសាទ | អួនកេវ ឬមងកេវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | គណៈកម្មការ និង សមាជិកសហគមន៍ នេសាទ |
| | | សន្ទូចរនងត្រី | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងបបែល | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | រនងផ្ទាក់មឹក | - | ៥០០គ្រ/គ្រួសារ | |
| | | សន្ទូចត្រីបេកា | - | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចដៃ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | | ឈិបរុញដោយដៃ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |
| | | រាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | រាវងាវភក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្តាមថ្ម ជ័រ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ, គ្រ = គ្រាប់)

**គ៥-ផែនការទប់ស្កាត់បទល្មើសជលផល**

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ៖<br>-តាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-បិទឯកសារ ១ដង/ឆ្នាំ<br>-ចែកឯកសារ<br>-ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១៥៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែ ឬឆមាស(មករានិងមិថុនា/រៀងរាល់ឆ្នាំ) | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ១៦៥ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | មករា ២០២៦ | ធ្នូ ២០២៨ |
| អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះបង្រ្កាបដល់ទីកន្លែងដោយទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធនិងអង្គការដៃគូ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១០៣៦៨ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| (៤ដង/ខែ = ១៤៤/ដង) | | | | | |
| មធ្យោបាយនិងសម្ភារ -សាំង និងប្រេងបាត -អាវ អាវភ្លៀង អាវពោង ពិល មួក កាតទូរស័ព្ទ អាយកូម ម៉ាស៊ីនថត កែវយឹត | មានលទ្ធភាពចុះល្បាតដោយ មានប្រសិទ្ធិភាព | ៣៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |
| ទិញទូកស្នាច់និងម៉ាស៊ីនថ្មី ចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ២០០០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |
| ទិញអូរប័រនិងម៉ាស៊ីន៤០ សេះ ចំនួន១គ្រឿង | | ៤០០០ | | | |
| គៀងគរថវិកាក្នុងការ ឧបបត្ថម្ភ ឬបដិភាគដល់ ប្រជានេសាទដែលឈប់ឬ ផ្លាស់ប្តូរការប្រើឧបករណ៍ នេសាទខុសច្បាប់ | កាត់បន្ថយការប្រើប្រាស់ឧបករណ៍ នេសាទខុសច្បាប់ | ៥០០០ | | មករា ២០២៦ | ធ្នូ ២០២៨ |

**គ៦-ផែនការកែលម្អកន្លែងកន្លែងសហគមន៍នេសាទ**

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ (ហិកតា) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ព្រៃកផ្លូវកណ្តាល | ៥ | ៥ម x ២០០០ម x ២ម | ប្រជុំផ្សព្វផ្សាយអង្គភាព អាជ្ញាធរនិង អ្នកពាក់ព័ន្ធ | ៥០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | ចុះសិក្សា និងវាយតម្លៃពីជំនាញពាក់ព័ន្ធ | ៨០០ | | |
| | | | កំណត់ទីតាំងស្តារជាក់ស្តែង | ២០០ | | |
| | | | ស្វែងរកដៃគូដើម្បីស្តារ | ៥០ | | |
| | | | ចុះគ្រឿងចក្រស្តារ ដោយដាក់លើសាឡង់ (អាចម៍ដីរៀបចំទុកដាក់នៅសង្ខាងព្រៃក) | ៣០០០០ | | |
| កន្លែងសហគមន៍ នេសាទជំពូខ្មៅ | ២៦៧០ | ២៦៧០ ហិកតា | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ និងអ្នកពាក់ព័ន្ធ | ៣០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | ចុះរកទីតាំងជាក់ស្តែងតាមនិយាមកា | ២០០ | | |
| | | | បោះបង្គោលព្រំប្រទល់កន្លែងសហគមន៍ នេសាទ ចំនួន ១៥ បង្គោល ធ្វើពីសីម៉ង់ ឆ្អឹងដែកទំហំ ២០ស.ម x៤០ស.ម x១,៥ម | ៣០០០ | | |
| ជម្រកសុវត្ថិភាព ស.នជំពូខ្មៅ 376876-1172257 | ៩ | ៩ ហិកតា | ផ្សព្វផ្សាយពីជម្រកសុវត្ថិភាពដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | ៨០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | រកទីតាំងជាក់ស្តែងតាមនិយាមកា និងពង្រាយ | ៥០០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| 376902-1172611<br>377145-1172544<br>377118-1172170 | | | ប្រអប់ជម្រកត្រីសិប្បនិម្មិត ធ្វើពីបេតុង ៥០ ប្រអប់ | | | |
| | | | បោះពោងព្រំជម្រកសុវត្ថិភាព៤ពោងធ្វើធុងជ័រ ខ្សែប្រវាក់និងចាក់ស៊ីម៉ង់ ដាក់ស្លាកសញ្ញា | ៦០០ | | |

(ស.ន = សហគមន៍នេសាទ, ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

## គ៧-ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំត្រូវអភិរក្ស (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| មាត់ពាម ឬជ្រោយថ្មី<br>375493-1175167<br>376316-1174935<br>376145-1174297<br>375333-1174557 | ៥៥ | -ព្រៃកោងកាង<br>-ក្តាមជ័រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលនិងហាមឃាត់ដល់ប្រជាពលរដ្ឋ ឱ្យបានទូលំទូលាយ | ៨០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | រកទីតាំងដាក់ស្តែងតាមនិយាមកា | ៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីគ្រឹះស៊ីម៉ង់បង្គោលដែក (សាជី) ចំនួន៤បង្គោល | ៣២០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងដែក ប្រក់ហ្វីប្រូស៊ីម៉ង់ | ៧០០ | | |
| ព្រែកផ្លូវកណ្តាល<br>375338-1173118<br>375649-1172953<br>375560-1172783<br>375231-1172952 | ៧ | -គ្រែងឈាម<br>-ជីវចម្រុះ | រកទីតាំងដាក់ស្តែងតាមនិយាមកា | ៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីគ្រឹះស៊ីម៉ង់បង្គោលដែក(សាជី) ចំនួន៤បង្គោល | ៣២០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងដែក ប្រក់ហ្វីប្រូស៊ីម៉ង់ | ៧០០ | | |
| | | | ពង្រាយប្រអប់ជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុងចំនួន៥០ ប្រអប់ | ៥០០០ | | |

## គ៨-ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះពងរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះពង ត្រូវរៀបចំឡើងដើម្បីបង្កើនផលស្តុកធម្មជាតិ នៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ (ហិកតា) | ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងកន្លែងសហគមន៍នេសាទជំពូខ្មៅ | ១<br>សាកល្បងជំហានទី១ទំហំ ២៥មx២៥ម | -ក្តាមសេះ<br>-ស្មៅសមុទ្រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្តាមសេះពង | ៣៦០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | សាងសង់ស្ថានីយ៍១កន្លែងនិងស្ពានដើរជុំវិញស្ថានីយ៍ធ្វើពីឈើ និងសម្ភារជាង | ៥៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងការពារក្តាមសេះ និងព័ទ្ធស្បៃមុង | ៥០០ | | |
| | | | ពង្រាយប្រអប់ថ្មបេតុងត្រីសិប្បនិម្មិតធ្វើពី ចំនួន១០ប្រអប់ថ្មបេតុង | ៤០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |
| | | | ព្រលែងកូនក្តាម និងមេក្តាមពង | ៥០០ | | |
| | | | ទិញឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់កូនក្តាមសេះ | ៥០០ | | |
| | | | ថែទាំ និងប្រមូលផល | ១០០ | | |

(ម = ម៉ែត្រ)

## គ៩-ផែនការគ្រប់គ្រងព្រៃកោងកាង

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងមានស្រាប់ ២១៤ ហិកតា | ២១៤ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងជាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | បោះបង្គោលព្រំព្រៃកោងកាង ធ្វើពីបេតុង ២០ស.ម x ២០ស.ម x ១,៥ម ចំនួន៨០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោងកាងសហគមន៍នេសាទ | | ១៦០០ | | |
| | | | សរសេរស្លាកសញ្ញាជាប់ នឹងបង្គោលព្រំព្រៃ | | ៣០០ | | |
| វាលភក់ស្ថិតក្នុងកន្លែងសហគមន៍នេសាទ | ២១ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងជាក់ស្តែងតាមនិយាមកា | | ២០០ | មករា | ធ្នូ |

| | | | | | | |
|---|---|---|---|---|---|---|
| ២១ ហិកតា | | | ដាក់ស្លាកសញ្ញាផែនទីព្រៃកោងកាង១ស្លាក ២,៥មx១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | ៨០០ | ២០២៦ | ២០២៨ |
| | | | រៀបចំថ្នាលបណ្តុះកូនកោងកាង បង្គោលឈើ និងស្បៃ ១០ម x ២០ម | ១០០០ | | |
| | | | បណ្តុះ ដាំនិងថែទាំដើមកោងកាង១១ហិកតា ៦៦០០០ដើម (១ហិកតា x ៦០០០ដើម) | ៦៦០០០ | | |
| | | | ដាំកូនកោងកាងចំនួន១៥នាក់x៨,៥ដុល្លារ/ថ្ងៃ | ៣០០០ | | |
| | | | ថែទាំដើមកោងកាង រយៈពេល៣ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ | ១០០០ | | |
| | | | ពី៣ខែដល់៦ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/អាទិត្យ | ១០០០ | | |
| | | | ពី៦ខែឡើងទៅ ៤នាក់x១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ | ១២០០ | | |

(ម = ម៉ែត្រ)

## ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

### គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹមគ្រែងឈាម | -មានចំណេះដឹងបច្ចេកទេសចិញ្ចឹម<br>-យកទៅអនុវត្តជាក់ស្តែងបាន<br>-មានមុខរបរ បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការ សមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ចិញ្ចឹមក្តាមថ្ម | | ៩០០ | | | |
| ចិញ្ចឹមខ្យងជំពុះទា | | ៩០០ | | | |
| ចិញ្ចឹមខ្យងងាវភក់ | | ៩០០ | | | |
| ចិញ្ចឹម(ឆ្លង់ តុកកែ កង្កែប អន្ទង់) | | ៩០០ | | | |
| កែច្នៃផលនេសាទ | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការ សមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| បច្ចេកទេសដាំបន្លែ | | ៩០០ | | | |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | | ៩០០ | | | |
| បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ | -មានចំណេះដឹង<br>-មានមុខរបរខ្នាតតូច ឬសិប្បកម្ម<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការ សមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទេសចរណ៍ជលផល | -ជំនាញស្តង់ដាម្ហូបអាហារ ផ្ទះស្នាក់<br>-ជំនាញស្តង់ដាអនាម័យ<br>-ជំនាញបដិសណ្ឋារកិច្ច | ១០០០ | គណៈកម្មការ សមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| បច្ចេកទេសនេសាទសមុទ្រខ្នាតមធ្យម និងខ្នាតធំ | -មានជំនាញការនេសាទសមុទ្រ<br>-មានមុខរបរនេសាទខ្នាតមធ្យម ធំ<br>-បង្កើនប្រាក់ចំណូល | ៣០០០ | គណៈកម្មការសមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ២.ទស្សនៈកិច្ចសិក្សា | -ដកស្រង់បទពិសោធន៍ជោគជ័យ<br>-មានចំណេះដឹងដើម្បីបង្កើតមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៣៥០០ | គណៈកម្មការសមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ៣.ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមគ្រែងឈាម | -មានក្រុមចិញ្ចឹមគ្រែងឈាម ក្តាមថ្ម ជំពុះទា ងាវភក់<br>-មានផលវារីវប្បកម្មផ្គត់ផ្គង់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការសមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ក្រុមចិញ្ចឹមខ្យងជំពុះទា | | ៥០០ | | | |
| ក្រុមចិញ្ចឹមក្តាមថ្ម | | ៥០០ | | | |
| ក្រុមចិញ្ចឹមខ្យងងាវភក់ | | ៥០០ | | | |
